ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថាន អាស៊ី អឺរ៉ុប

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញ លិខិតស្នើសុំរបស់ លោក ឌួង លាង នាយកវិទ្យាស្ថានអាស៊ីអឺរ៉ុប ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣
- បានឃើញយោបល់របស់ ក្រសួងអប់រំ យុវជន និង កីឡា

# សំ រេ ច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា " **វិទ្យាស្ថាន អាស៊ី អឺរ៉ុប** " **"ASIA EURO INSTITUTE"** ហៅកាត់ជាភាសាខ្មែរ "វ.អ.អ " និងហៅជាភាសាអង់គ្លេស **"AEI"** ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោល ស្ថិតនៅ អាគារលេខ ៨៣២ ABCD ផ្លូវ ១២៨ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថានអាស៊ីអឺរ៉ុប ធ្វើការបណ្តុះបណ្តាល កំរិតបរិញ្ញាប័ត្ររង ដែលមានរយៈពេល សិក្សាយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ក្រេឌីត ជាមធ្យម និង កំរិតបរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១៥០ ក្រេឌីត ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថាន អាស៊ី អឺរ៉ុប មានមហាវិទ្យាល័យ :

១- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម

២- មហាវិទ្យាល័យ នីតិសាស្ត្រ និង វិទ្យាសាស្ត្រនយោបាយ

៣- មហាវិទ្យាល័យ សេដ្ឋកិច្ច

៤- មហាវិទ្យាល័យ បច្ចេកវិទ្យាព័ត៌មាន

៥-មហាវិទ្យាល័យ អប់រំ

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស កំរិត ប្រភេទបណ្តុះបណ្តាល ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានអាស៊ីអឺរ៉ុប មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និងសំរេចលើគោលនយោបាយ ផែនការអភិវឌ្ឍ របស់វិទ្យាស្ថាន និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** ល័ក្ខខ័ណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុតបានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រ ដែលមានតំលៃស្មើ ។

វិទ្យាស្ថាន អាស៊ី អឺរ៉ុប ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** នាយកវិទ្យាស្ថាន អាស៊ី អឺរ៉ុប មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។

- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារបណ្តុះបណ្តាល ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និងអនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាន អាស៊ី អឺរ៉ុប និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្របរិញ្ញាប័ត្ររង និង សញ្ញាប័ត្របរិញ្ញា តាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយវិទ្យាស្ថាន អាស៊ី អឺរ៉ុប ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងវិទ្យាស្ថាន អាស៊ី អឺរ៉ុប មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនដំណឹង"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ